ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 03-Apr-2015, 15:04
CMS/CFO: Sann Rada

**នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល**
**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**
**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| **សំណុំរឿងលេខ** | : | ០០២/១៩-០៩-២០០៧-អវតក/អជតក |
| **ដាក់ទៅ** | : | អង្គជំនុំជម្រះតុលាការកំពូល |
| **ថ្ងៃដាក់** | : | ថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៥ |
| **ភាគីអ្នកដាក់** | : | សហព្រះរាជអាជ្ញាអន្តរជាតិ |
| **ភាសាដើម** | : | **អង់គ្លេស** |

**ចំណាត់ថ្នាក់ឯកសារ**

**ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ** អមដោយ **ឧបសម្ព័ន្ធសាធារណៈ**:មួយ

**ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះតុលាការកំពូល:** សាធារណៈ/Public

**ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:**

**ការពិនិត្យចំណាត់ថ្នាក់ឯកសារបណ្តោះអាសន្នឡើងវិញ:**

**ឈ្មោះមន្ត្រីដែលបានពិនិត្យ:**

**ហត្ថលេខា:**

---

**ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល លេខ F2/4/2 ទាក់ទងនឹងការដាក់បង្ហាញឯកសារ**

---

**អ្នកដាក់ឯកសារ:**

**សហព្រះរាជអាជ្ញា:**

លោក Nicholas KOUMJIAN

**ចម្លងជូន:**

លោកស្រី ជា លាង

**អ្នកទទួលឯកសារ:**

**អង្គជំនុំជម្រះតុលាការកំពូល:**

ចៅក្រម គង់ ស្រីម, ប្រធាន

ចៅក្រម A. KLONOWIECKA- MILART

ចៅក្រម សោម សិរីវឌ្ឍ

ចៅក្រម C. N. JAYASINGHE

ចៅក្រម ម៉ុង មុនីចរិយា

ចៅក្រម យ៉ា ណារិន

ចៅក្រម Florence Ndepele NUMBA

**ចម្លងជូន:**

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី:**

ពេជ អង្គ

Marie GUIRAUD

**ជនជាប់ចោទ:**

នួន ជា

ខៀវ សំផន

**មេធាវីការពារក្តីជនជាប់ចោទ:**

លោក សុន អរុណ

លោក Victor KOPPE

លោក គង់ សំអុន

លោក Anta GUISSÉ

លោក Arthur VERCKEN

**មេធាវីប្រចាំការ:**

លោកស្រី ទូច វល័ក្ស

លោក Calvin SAUNDERS

## I. សេចក្តីផ្តើម

1. សេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល "សេចក្តីសម្រេចលើផ្នែកខ្លះនៃសំណើលើកទីបីរបស់ នួន ជា សុំឱ្យទទួលយក និងពិចារណាទៅលើភស្តុតាងបន្ថែម ក្នុងកិច្ចដំណើរការនីតិវិធីលើបណ្តឹងសាទុក្ខក្នុងសំណុំរឿង០០២/០១"[1] ("សេចក្តីសម្រេច") បានផ្តល់នូវសេចក្តីសម្រេច និងការណែនាំខុសៗគ្នា ដល់សហព្រះរាជអាជ្ញា ទាក់ទងនឹងការបង្ហាញព័ត៌មានក្រៅពីកំណត់ហេតុសវនាការសំខាន់បំផុត គឺសម្ភារៈទទួលបានពីកិច្ចស៊ើបសួរក្នុងសំណុំរឿង០០៣ និង០០៤ ដែលកំពុងដំណើរការដល់ភាគីនានា និងអង្គជំនុំជម្រះ ក្នុងបណ្តឹងសាទុក្ខនៃសំណុំរឿង០០២/០១។ ដើម្បីឆ្លើយតបទៅនឹងសេចក្តីសម្រេច និងការណែនាំទាំងនេះ សហព្រះរាជអាជ្ញាអន្តរជាតិសូមបំភ្លឺអំពីការអនុវត្ត និងចំណាត់ការនានាដែលបានធ្វើកន្លងមក អំពីសម្ភារៈណាខ្លះដែលបានដាក់បង្ហាញរហូតមកដល់បច្ចុប្បន្ន និងអំពីសកម្មភាពទាំងឡាយដែលសហព្រះរាជអាជ្ញាមានផែនការអនុវត្តក្នុងពេលអនាគត ដើម្បីបំពេញកាតព្វកិច្ចក្នុងការដាក់បង្ហាញឯកសាររបស់ខ្លួន និងអនុវត្តតាមការណែនាំដែលមាននៅក្នុងសេចក្តីសម្រេចនេះ។

## II. ការដាក់បង្ហាញរហូតដល់បច្ចុប្បន្ន

2. ជាបឋម សហព្រះរាជអាជ្ញាសូមបំភ្លឺថាតាំងពីដើមរៀងមក ការពិនិត្យទៅលើសំណុំរឿង០០៣ និង០០៤ ដើម្បីស្វែងរកភស្តុតាងសម្រាប់ដាក់បង្ហាញក្នុងសំណុំរឿង០០២ គឺមានទាំងការពិនិត្យទៅលើសម្ភារៈដោះបន្ទុកសក្តានុពលនានា ដែលពាក់ព័ន្ធនឹងបញ្ហាផ្សេងៗក្នុងសំណុំរឿង០០២/០១ផងដែរ។ ដោយសារកាតព្វកិច្ចដាក់បង្ហាញឯកសាររបស់សហព្រះរាជអាជ្ញាមិនត្រូវបានកម្រិត ឬកំណត់ត្រឹមសំណើជាក់លាក់ណាមួយរបស់មេធាវីការពារក្តី ការពិនិត្យដែលបានធ្វើឡើងចំពោះសម្ភារៈដែលត្រូវដាក់បង្ហាញពីសំណុំរឿង០០៣ និង០០៤នោះ តែងតែគ្របដណ្តប់លើគ្រប់បញ្ហាទាំងអស់ដែលជាប់ទាក់ទងនឹងសំណុំរឿង០០២ រួមទាំងបញ្ហាពាក់ព័ន្ធនឹងសំណុំរឿង០០២/០១ផង។ ឧទាហរណ៍ការពិនិត្យដែលឈានដល់ការកំណត់អត្តសញ្ញាណ និងសំណើសុំបង្ហាញកំណត់ហេតុស្តាប់ចម្លើយពាក់ព័ន្ធនឹងទាហាន និងមន្ត្រីរដ្ឋការ លន់ នល់ ដែលត្រូវបានគេធ្វើទុក្ខបុកម្នេញ និងសម្លាប់ដោយ

[1] **F2/4/2** សេចក្តីសម្រេចលើផ្នែកខ្លះនៃសំណើលើកទីបីរបស់ នួន ជា សុំទទួលយក និងពិចារណាទៅលើភស្តុតាងបន្ថែមក្នុងកិច្ចដំណើរការនីតិវិធីលើបណ្តឹងសាទុក្ខក្នុងសំណុំរឿង០០២/០១, ១៦ មីនា ២០១៥(ចាប់ពីនេះតទៅហៅថា "សេចក្តីសម្រេច")។

បកក[2] រួមមានទាំងភស្តុតាងអំពីការសម្លាប់នៅទួលពោធិ៍ជ្រៃ ថ្វីបើមេធាវីការពារក្តីមិនធ្លាប់បានស្នើជាក់លាក់ឲ្យដាក់បង្ហាញសម្ភារៈដូច្នេះក៏ដោយ។ ការពិនិត្យដែលបានធ្វើឡើងដោយសហព្រះរាជអាជ្ញាលើសំណុំរឿង០០៣ និង០០៤ ដោយបានពង្រីករហូតដល់ឯកសារដោះបន្ទុកចំពោះការជម្លៀសដោយបង្ខំលើកទី១ និងទី២ រួមទាំងកំណត់ហេតុស្តាប់ចម្លើយដែលអាចបង្ហាញពីព្រឹត្តិការណ៍នានាដូចបានចោទប្រកាន់នៅក្នុងដីកាដំណោះស្រាយ ឬបានរកឃើញនៅក្នុងសាលក្រមនោះ មិនបានកើតឡើងទេ[3]។

3. ទាក់ទិននឹងភស្តុតាងដែលគួរឆ្លើយតបទៅតាមសំណើជាក់លាក់របស់ នួន ជា ពាក់ព័ន្ធនឹងភូមិភាគពាយ័ព្យ ការពិនិត្យបានកំណត់អត្តសញ្ញាណ និងបានស្នើឲ្យមានការបង្ហាញសម្ភារៈដែលពាក់ព័ន្ធនឹងការបោសសម្អាតកម្មាភិបាលភូមិភាគពាយ័ព្យ រួមទាំងសម្ភារៈដែលពាក់ព័ន្ធនឹងសម្ព័ន្ធភាពរវាងសិទ្ធិអំណាចរបស់មេដឹកនាំភូមិភាគពាយ័ព្យ រស់ ញឹម និងមេដឹកនាំមជ្ឈិមបក្សនិមួយៗ។ ការពិនិត្យនេះរួមមានការស្រាវជ្រាវមួយស្វែងរកសេចក្តីយោងទៅរក "ញឹម" (និងការប្រកបឈ្មោះគាត់តាមរបៀបផ្សេង) ក្នុងកំណត់ហេតុស្តាប់ចម្លើយនៃសំណុំរឿង០០៣ និង០០៤។ ហេតុដូច្នេះ សហព្រះរាជអាជ្ញាក៏បានស្នើដាក់បង្ហាញកំណត់ហេតុស្តាប់ចម្លើយរបស់បុគ្គលម្នាក់ៗ ដែលធ្លាប់ធ្វើការជាមួយ រស់ ញឹម ដោយផ្ទាល់ ព្រមទាំងកំណត់ហេតុទាំងឡាយរបស់កម្មាភិបាលដែលនៅរស់ផ្សេងទៀតដែលធ្លាប់កាន់មុខតំណែងសំខាន់ៗនៅភូមិភាគពាយ័ព្យ (មិនថាពួកគាត់ធ្លាប់ ឬមិនធ្លាប់ ធ្វើការជាមួយ រស់ ញឹម ដោយផ្ទាល់នោះទេ)។ ក្នុងការពិនិត្យសម្រាប់ការដាក់បង្ហាញនេះ សហព្រះរាជអាជ្ញាបានធ្វើប្រតិបត្តិការដោយមានការយល់ថា នួន ជា នៅតែបន្តដាក់ទៅក្នុងសំណុំរឿង០០២/០១ និង០០២/០២ នូវការជំទាស់របស់គាត់ថា "បកក គឺជាបក្សដែលមានការបែកបាក់គ្នាបំផុត ដោយ រស់ ញឹម នៅគ្រប់គ្រងអំណាចដោយឯករាជ្យនៅលើឧក្រិដ្ឋកម្មទាំងឡាយ ដែលមានការជាប់ពាក់ព័ន្ធនឹង នួន ជា នៅក្នុងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង"[4] ហើយយោងតាមនេះក៏បានកំណត់

---

[2] ដោយហេតុថា នេះជាប្រធានបទមួយពាក់ព័ន្ធនឹងបណ្តឹងសាទុក្ខនៃសំណុំរឿង០០២/០១ផង និងឧក្រិដ្ឋកម្មនានាដែលបាន និងកំពុងធ្វើការជំនុំជម្រះដោយអង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង០០២/០២ផង សហព្រះរាជអាជ្ញាបានស្នើសុំដាក់បង្ហាញកំណត់ហេតុទាំងអស់ដែលពាក់ព័ន្ធនឹងបញ្ហានេះ ទោះបីជាដោះបន្ទុក ឬដាក់បន្ទុកក៏ដោយ។

[3] ដោយសារបញ្ហាជាក់លាក់ទាំងអស់នេះ ជាបញ្ហាពិសេសចំពោះបណ្តឹងសាទុក្ខនៃសំណុំរឿង០០២/០១ និងមិនពាក់ព័ន្ធនឹងបញ្ហាដែលបាន និងកំពុងជំនុំជម្រះក្នុងសំណុំរឿង០០២/០២ សពអ បានកម្រិតចំពោះការពិនិត្យឡើងវិញសម្រាប់ការបង្ហាញនៅលើប្រធានបទនេះ តែសម្ភារៈណាដែលមានចរិកលក្ខណៈដោះបន្ទុក ឬភស្តុតាងថ្មីពិសេសប៉ុណ្ណោះ។

[4] **F2/4/2** សេចក្តីសម្រេច, កថាខណ្ឌ ១៩។

អត្តសញ្ញាណ និងស្នើបង្ហាញភ័ស្តុតាងណាដែលមានការពាក់ព័ន្ធនឹងការប្រឆាំងនឹង ប៉ុល ពត និង នួន ជា នៅភូមិភាគពាយ័ព្យ។

4. ទាក់ទិននឹងស្ថានភាពនៃសំណើសុំដាក់បង្ហាញឯកសាររបស់សហព្រះរាជអាជ្ញា រហូតមកដល់ពេលនេះ ការិយាល័យសហចៅក្រមស៊ើបអង្កេតបានដឹកនាំស្តាប់ចម្លើយសាក្សីចំនួន៦៤៨ ក្នុងសំណុំរឿង ០០៤ ជាករណីដែលឧក្រិដ្ឋកម្មនានានៅភូមិភាគពាយ័ព្យកំពុងត្រូវបានស៊ើបអង្កេត។ ក្នុងចំណោមកំណត់ហេតុទាំងនោះ មានកំណត់ហេតុចំនួន៤១៨ ត្រូវបានដាក់បង្ហាញរួចហើយទៅភាគីនៃសំណុំរឿង០០២។ ជាការបន្ថែម សហព្រះរាជអាជ្ញា បានដាក់សំណើនានា ដែលពេលនេះ កំពុងរង់ចាំការសម្រេចរបស់ សចសអ ដើម្បីដាក់បង្ហាញកំណត់ហេតុស្តាប់ចម្លើយសាក្សីចំនួន៨១ បន្ថែមទៀតពីសំណុំរឿង០០៤ បើទោះជាមានការកត់សម្គាល់ថា កំណត់ហេតុចំនួន៥៥ នៃកំណត់ហេតុទាំងនោះ ជាកំណត់ហេតុថ្មី ដែលស្ថិតក្នុងសំណើដាក់បង្ហាញ ដែលទើបបានដាក់កាលពីថ្ងៃទី១២ និង២៣ ខែមីនា ឆ្នាំ២០១៥ ហើយសល់តែ២៦កំណត់ហេតុប៉ុណ្ណោះ ដែលត្រូវការអនុញ្ញាតពីសំណើសុំដាក់បង្ហាញលើកមុនៗដែលបានដាក់ក្នុងខែឧសភា និងខែធ្នូ ឆ្នាំ២០១៤។ មានកំណត់ហេតុស្តាប់ចម្លើយថ្មីប្រមាណ២០ ដែលបានដាក់ក្នុងសំណុំរឿង០០៤កាលពីពីរទៅបីសប្តាហ៍កន្លងមក បច្ចុប្បន្នកំពុងពិនិត្យវាយតម្លៃសម្រាប់ការដាក់បង្ហាញ។ កំណត់ហេតុស្តាប់ចម្លើយចំនួន១២៩ដែលនៅសល់ត្រូវបានកំណត់ថាមិនពាក់ព័ន្ធសម្រាប់ការដាក់បង្ហាញទេ ក្នុងការពិនិត្យមួយដែលបានធ្វើឡើង ដោយសហព្រះរាជអាជ្ញាក្នុងសំណុំរឿងនោះ។

5. មានកំណត់ហេតុស្តាប់ចម្លើយសាក្សីបន្ថែមចំនួន១៤៧ទៀត ដែលមានលក្ខណៈពិសេសសម្រាប់តែសំណុំរឿង០០៣។ បើប្រៀបធៀបទៅនឹងសំណុំរឿង០០៤ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានអនុញ្ញាតឲ្យបង្ហាញតែកំណត់ហេតុស្តាប់ចម្លើយមួយចំនួនតូចប៉ុណ្ណោះពីការស៊ើបអង្កេតនៃសំណុំរឿង ០០៣ (មានតែប្រាំមួយកំណត់ហេតុទេរហូតមកដល់ពេលនេះ) ដោយសារមានការព្រួយបារម្ភជាពិសេសអំពីការរក្សាសម្ងាត់របស់សាក្សីនៅក្នុងកិច្ចស៊ើបសួរនោះ។ ដោយសារតែកិច្ចស៊ើបសួរក្នុងសំណុំរឿង០០៣មិនបញ្ចូលទីតាំងឧក្រិដ្ឋកម្មណាមួយនៅភូមិភាគពាយ័ព្យ ដូច្នេះឯកសារនានាពីសំណុំរឿងនោះ មិនត្រូវបានគេរំពឹងថា មានព័ត៌មានពាក់ព័ន្ធនឹងសំណើជាក់លាក់របស់ នួន ជា ទេ។ យ៉ាងណាក៏ដោយ ឯកសារពីសំណុំរឿងនោះ ក៏បានឆ្លងកាត់ដំណើរការត្រួតពិនិត្យដូចគ្នានឹងឯកសារក្នុងសំណុំរឿង០០៤ដែរ។ ក្នុងចំណោមកំណត់ហេតុស្តាប់ចម្លើយសាក្សីនៃសំណុំរឿង០០៣របស់ កសចស ចំនួន១៤១ ដែលមិនទាន់បានដាក់បង្ហាញនៅឡើយ កំណត់ហេតុចំនួន៥៣ មានសំណើសុំបង្ហាញរួចហើយដែលកំពុងរង់ចាំការសម្រេចរបស់ កសចស កំណត់ហេតុ២ដែលទើបបានដាក់នាពេលថ្មីៗ

នេះ គឺជាកំណត់ហេតុដែលបានពិនិត្យ និងវាយតម្លៃ ហើយចំណែកកំណត់ហេតុចំនួន៨៦ទៀត ត្រូវបានកំណត់ថាមិនពាក់ព័ន្ធសម្រាប់ការដាក់បង្ហាញក្នុងសំណុំរឿង០០២ទេ។

6. សហព្រះរាជអាជ្ញាក៏បានកត់សម្គាល់ផងដែរថា តាមរយៈអង្គជំនុំជម្រះសាលាដំបូង សហព្រះរាជអាជ្ញាធ្លាប់បានធ្វើការដាក់បង្ហាញទាំងនេះចូលទៅក្នុងសំណុំរឿង០០២/០២ ពីព្រោះសម្ភារៈទាំងអស់ដែលបានកំណត់អត្តសញ្ញាណសម្រាប់ធ្វើការដាក់បង្ហាញ គឺសុទ្ធតែមានភាពពាក់ព័ន្ធយ៉ាងជាក់លាក់ទៅនឹងសវនាការដែលកំពុងដំណើរការនេះ ហើយសព្វថ្ងៃ ពុំមានឯកសារណាមួយដែលបានកំណត់អត្តសញ្ញាណសម្រាប់ធ្វើការដាក់បង្ហាញ មានការពាក់ព័ន្ធនឹងសំណុំរឿង០០២/០១ទេ។ សហព្រះរាជអាជ្ញាបានទទួលស្គាល់អង្គហេតុពិតដែលថាភាគីនានានៅក្នុងសំណុំរឿង០០២/០២ គឺជាភាគីជានៅក្នុងសំណុំរឿង០០២/០១ដែរ ហើយការដាក់បង្ហាញដល់ភាគីនានា នៅក្នុងសំណុំរឿង០០២/០២ គឺបានផ្តល់ជូនដល់ពួកគាត់យ៉ាងមានប្រសិទ្ធភាពនូវការ ដែលអាចបើកមើលឯកសារពាក់ព័ន្ធទាំងឡាយដែលពួកគាត់អាចវាយតម្លៃ និងសម្រេចចិត្តថាតើត្រូវស្វែងរកសុំការអនុញ្ញាតពីអង្គជំនុំជម្រះនេះដែរឬទេ ពាក់ព័ន្ធនឹងបណ្តឹងសាទុក្ខលើសំណុំរឿង០០២/០១។

7. ឧបសម្ពន្ធនានាដែលសហព្រះរាជអាជ្ញាបានផ្តល់ជូនអង្គជំនុំជម្រះសាលាដំបូង និងភាគីនានា ដោយមានឯកសារដែលបានដាក់បង្ហាញនានា មាននៅក្នុងជួរមួយដែលមានចំណងជើងថា "មូលហេតុនៃការដាក់បង្ហាញ" ដែលបានឆ្លុះបញ្ចាំងផ្នែកនានានៃដីកាដំណោះស្រាយនៅក្នុងសំណុំរឿង០០២ ដែលឯកសារនីមួយៗមានការពាក់ព័ន្ធទៅនឹងផ្នែកទាំងនោះ (*ឧទា.* ទីកន្លែងសម្លាប់មនុស្សនៅទួលពោធិ៍ជ្រៃ ការជម្លៀសប្រជាជនពីទីក្រុងភ្នំពេញ ការបោសសម្អាត ប្រព្រឹត្តិកម្មលើក្រុមគោលដៅនានា) ដូចដែលបានភ្ជាប់នៅក្នុងទិន្នន័យនៃ CaseMap របស់សហព្រះរាជអាជ្ញា។ ឯកសារទាំងឡាយដែលបានកំណត់អត្តសញ្ញាណថាមានលក្ខណៈឆ្លើយតបទៅនឹងសំណើជាក់លាក់របស់ នួន ជា ក៏ត្រូវបានដាក់សម្គាល់នៅក្នុងជួរនោះផងដែរថា "ឆ្លើយតបទៅនឹងឯកសារ F2/4" ឬមួយ "អាចមានការពាក់ព័ន្ធនឹងបណ្តឹងសាទុក្ខលើសំណុំរឿង០០២/០១ (ប្រភេទឯកសាររបស់មេធាវីការពារក្តី)"។ ដូច្នេះ កិច្ចប្រឹងប្រែងសុចរិតមួយត្រូវបានធ្វើដោយសហព្រះរាជអាជ្ញា ដើម្បីធានាថាមេធាវីការពារក្តីបាន ដឹងអំពីសម្ភារៈនានាដែល នួន ជា យល់ឃើញថាមានការពាក់ព័ន្ធជាសក្តានុពលទៅនឹងបណ្តឹងសាទុក្ខលើសំណុំរឿង០០២/០១ ក៏ត្រូវបានដាក់បង្ហាញដែរ។

8. សហព្រះរាជអាជ្ញាសូមបញ្ជាក់ម្តងទៀតពីគោលជំហររបស់ខ្លួនថា សំណើរបស់ នួន ជា ស្នើសុំភស្តុតាងទាំងអស់ស្តីពី (១) បុគ្គលនានាដែលបានធ្វើការផ្ទាល់ជាមួយ រស់ ញឹម, និង (២) ភស្តុតាង

ពីភូមិភាគពាយ័ព្យ រហូតដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ ដែលប្រឆាំងនឹង នួន ជា និង ប៉ុល ពត គឺច្បាស់ណាស់បានទៅហួសពីសំណើសុំដាក់សម្ភារៈដោះបន្ទុក ដែលទាក់ទងនឹងបញ្ហានានានៃបណ្តឹងសាទុក្ខលើសំណុំរឿង០០២/០១។ ដូចដែលសហព្រះរាជអាជ្ញាធ្លាប់បានយល់ឃើញពីមុនដូច្នោះដែរ គឺ "កំណត់ហេតុស្តាប់ចម្លើយសាក្សីដែលបានកំណត់ដោយមេធាវីការពារក្តី នួន ជា ពង្រីកដល់កំណត់ហេតុសម្ភាសន៍ នៅពេលពាក់ព័ន្ធនឹងសំណុំរឿងលេខ០០២/០២ អាចមិនមែនជាភស្តុតាងដែលដោះបន្ទុក ចំពោះបណ្តឹងសាទុក្ខក្នុងសំណុំរឿងលេខ០០២/០១"[5]។ យ៉ាងណាក៏ដោយ ជាការគួរសមជាមួយ នួន ជា នៅពេលដែលបានទទួលសំណើរបស់គាត់ដែលដាក់ជូនទៅអង្គជំនុំជម្រះ ដែលនៅក្នុងសំណើនោះ គាត់បានកំណត់អត្តសញ្ញាណភស្តុតាងពីរប្រភេទដែលគាត់បានគិតថាដោះបន្ទុក[6] សហព្រះរាជអាជ្ញាបានចាប់ផ្តើមស្នើសុំអាទិភាពដើម្បីធ្វើការពិនិត្យឡើងវិញនូវឯកសារ ដែលបានដឹងនានាបានឆ្លើយតបទៅនឹងប្រភេទភស្តុតាងរបស់ នួន ជា សូម្បីតែមានក៏ដោយ បើតាមទស្សនៈរបស់សហព្រះរាជអាជ្ញាតាមធម្មតាមិនស្ថិតនៅក្រោមការដាក់បង្ហាញ ដែលទាក់ទងនឹងបទចោទនានានៃសំណុំរឿង០០២/០១ទេ ពីព្រោះសហព្រះរាជអាជ្ញាមិនមានភស្តុតាងដែលអាចនាំឲ្យមានលក្ខណៈសម្រាលទោស ដោះបន្ទុក ឬប៉ះពាល់ដល់សុចរិតភាពនៃភស្តុតាង នៅក្នុងសំណុំរឿងនោះឡើយ។ ដើម្បីចៀសវាងទំនាស់ និងជួយសម្រួលដល់នីតិវិធីនៃការដាក់បង្ហាញ សហព្រះរាជអាជ្ញានឹងបន្តស្នើសុំអាទិភាពក្នុងការដាក់បង្ហាញឯកសារនានាដែលស្ថិតនៅក្នុងប្រភេទទាំងឡាយរបស់ នួន ជា ឬម្យ៉ាងវិញទៀតឯកសារទាំងនោះត្រូវបានចាត់ទុកថាត្រូវការដាក់បង្ហាញ សម្រាប់បណ្តឹងសាទុក្ខ លើសំណុំរឿង០០២/០១។

## III. ដំណាក់កាលសម្រេចពាក់ព័ន្ធនឹងឯកសារចំនួនពីរ

9. ពាក់ព័ន្ធនឹងឯកសារចំនួនពីរដែលអង្គជំនុំជម្រះបានពិភាក្សានៅក្នុងកថាខណ្ឌ២១ និង២៣ នៃសេចក្តីសម្រេច សហព្រះរាជអាជ្ញាសូមជូនដំណឹងដល់អង្គជំនុំជម្រះថា ឯកសារទាំងពីនោះបានដាក់បញ្ចូល

---

[5] **F2/4/1** ចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹងសំណើលើកទីបីរបស់ នួន ជា សុំឲ្យធ្វើការពិចារណា និងទទួលយកភស្តុតាងបន្ថែម ទាក់ទងបណ្តឹងសាទុក្ខប្រឆាំងសាលក្រមអង្គជំនុំជម្រះសាលាដំបូង ក្នុងសំណុំរឿង០០២/០១, ១៩ ធ្នូ ២០១៤, កថាខណ្ឌ ១៥។

[6] **F2/4** សំណើលើកទីបីរបស់ នួន ជា សុំឲ្យធ្វើការពិចារណា និងទទួលយកភស្តុតាងបន្ថែម ទាក់ទងបណ្តឹងសាទុក្ខប្រឆាំងសាលក្រមអង្គជំនុំជម្រះសាលាដំបូង ក្នុងសំណុំរឿង០០២/០១, ២៥ វិច្ឆិកា ២០១៤។

ទៅក្នុងការដាក់បង្ហាញមួយជូនដល់ភាគីនានានៃសំណុំរឿង០០២រួចហើយ ដោយសហព្រះរាជអាជ្ញា កាលពីថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៥[7]។

10. ដូចបានបង្គាប់ដូច្នោះដែរ[8] ប្រសិនបើមានឯកសារបន្ថែមដែលបានកំណត់អត្តសញ្ញាណថាស្ថិតនៅក្នុងប្រភេទដែល នួន ជា បានស្នើសុំ ត្រូវបានការិយាល័យសហចៅក្រមស៊ើបអង្កេត បដិសេធមិនព្រមឲ្យដាក់បង្ហាញ នោះសហព្រះរាជអាជ្ញានឹងស្នើសុំថា ឯកសារទាំងនោះត្រូវដាក់បង្ហាញទៅអង្គជំនុំជម្រះតុលាការកំពូល ថាជាឯកសារសម្ងាត់បំផុត។

## IV. ចំណាត់ការបន្ថែម

11. ទោះបីជាការដាក់បង្ហាញឯកសារពិនិត្យឡើងវិញរួចហើយដោយសហព្រះរាជអាជ្ញាក៏ដោយ ឯកសារទាំងនោះបានដាក់បញ្ចូលទៅក្នុងបញ្ជីនានានៃសំណុំរឿង០០២/០១ ហើយនឹងត្រូវបានកំណត់អត្តសញ្ញាណ និងដាក់បញ្ចូលទៅក្នុងប្រភេទជាក់លាក់ដែលបានស្នើឡើងដោយ នួន ជា សហព្រះរាជអាជ្ញានឹងដំណើរការបន្តទៀតដោយការយកចិត្តទុកដាក់ដើម្បីបញ្ជាក់ថា ឯកសារទាំងឡាយនៃសំណុំរឿង០០៣ និង០០៤ ដែលមិនទាន់បានដាក់បង្ហាញ ឬមិនទាន់បានស្នើសុំដាក់បង្ហាញនៅឡើយគឺជាឯកសារដែលមិនឆ្លើយតបទៅនឹងសំណើរបស់ នួន ជា ឡើយ ហើយនឹងស្វែងរកធ្វើការដាក់បង្ហាញឯកសារទាំងនោះ នៅពេលដែលមានឯកសារបន្ថែមទៀតត្រូវបានកំណត់ថាមានលក្ខណៈឆ្លើយតប។ សហព្រះរាជអាជ្ញានឹងធ្វើដូច្នេះឲ្យបានឆាប់តាមដែលអាចធ្វើទៅបាន។ យ៉ាងណាក៏ដោយ សហព្រះរាជអាជ្ញាកត់សម្គាល់ថានៅពេលបច្ចុប្បន្ននេះ សហព្រះរាជអាជ្ញាបានជាប់រវល់នឹងការព្រាងសារណាចម្លើយតបរួមរបស់ខ្លួន នៅក្នុងបណ្តឹងសាទុក្ខលើសំណុំរឿង០០២/០១ ជួនពេលគ្នាជាមួយនឹងការចូលរួមនៅក្នុងសវនាការលើសំណុំរឿង០០២/០២ ព្រមទាំងចូលរួមចំណែកនៅក្នុងការស៊ើបអង្កេតដែលកំពុងបន្ត និងការបង្កើនពាក្យបណ្តឹងនៅក្នុងសំណុំរឿង០០៣ និង០០៤ ផងដែរ។ ខណៈដែលសហព្រះរាជអាជ្ញាបានទទួលស្គាល់ពីសារៈសំខាន់ និងភាពបន្ទាន់នៃកាតព្វកិច្ច ក្នុងការដាក់បង្ហាញឯកសារ នោះការពិតគឺថា ធនធានសំខាន់ដែលបានដាក់សម្រាប់ធ្វើកិច្ចការនេះ នឹងត្រូវបានដកហូតសមត្ថភាពចេញពីការបំពេញកាតព្វកិច្ចដទៃទៀត។

[7] **E319/19** ការដាក់បង្ហាញរបស់សហព្រះរាជអាជ្ញាអន្តរជាតិនូវឯកសារពីសំណុំរឿង០០៤ ដែលពាក់ព័ន្ធនឹងសំណុំរឿង០០២ អនុលោមតាមសំណុំរឿង០០៤-D193/15, ១៨ មីនា ២០១៥។

[8] **F2/4/2** សេចក្តីសម្រេច, ត្រង់កថាខណ្ឌ ២៤។

12. សហព្រះរាជអាជ្ញាក៏កត់សម្គាល់ផងដែរថា ការកត់សម្គាល់របស់អង្គជំនុំជម្រះ ដែលថាសហព្រះរាជអាជ្ញានៅមិនទាន់បានដាក់សំណៅកោសល្យុបនៃឯកសារ F2/4/1[9]។ សហព្រះរាជអាជ្ញាមានការសោកស្តាយពីការខកខាននេះ ហើយបានភ្ជាប់សំណៅកោសល្យុបក្នុង **ឧបសម្ព័ន្ធ ក** មកជាមួយនេះផងដែរ៕

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៥ | **លោក Nicholas KOUMJIAN**<br>សហព្រះរាជអាជ្ញា | ភ្នំពេញ | |

[9] **F2/4/2** សេចក្តីសម្រេច, ត្រង់កំណត់សម្គាល់ជើងទំព័រលេខ ២។